ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២០-០០៤ សរ.ន.ណន

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

# សារាចរណែនាំបន្ថែម
# ស្តីពី
# ការអនុវត្តប្រកាសស្តីពី
# ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងតាមប្រកាសលេខ ធ៧-០១៨-០៦៨ ប្រ.ក ចុះថ្ងៃព្រហស្បតិ៍ ៨ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាសូមណែនាំអំពីការអនុវត្តខ្លឹមសារនៃប្រកាសនេះ ដូចខាងក្រោម៖

## ១. ការពន្យល់បន្ថែមអំពីនិយមន័យនៃប្រាក់ចំណេញ

***ប្រការ ៤.-***

*[...] ប្រាក់ចំណេញ សំដៅដល់ប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុដែលអាចបែងចែកបាន ដោយត្រូវបានគណនាមុនពេលដកចេញនូវធាតុដែលមិនអាចបែងចែកផ្សេងៗ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។ ប្រាក់ចំណេញត្រូវបានគណនាក្រោយការបង់ពន្ធ ដែលត្រូវបានរាយការណ៍មុនពេលដកចេញនូវធាតុដែលអាចបែងចែកបាន។ ដូច្នេះ ផលប៉ះពាល់លើកាតព្វកិច្ចបង់ពន្ធ ត្រូវគណនាសារឡើងវិញ នៅពេលដែលមានការបែងចែកប្រាក់ចំណេញ។*

ប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ សំដៅដល់ប្រាក់ចំណេញសុទ្ធដែលរាយការណ៍ក្នុងរបាយការណ៍ប្រចាំខែស្តីពី ចំណូល និងចំណាយនៅក្នុងខែធ្នូ (ខ្ទង់ "ចំណេញ/ខាត សុទ្ធក្នុងគ្រា") ប៉ុន្តែនៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានធ្វើសវនកម្មរួច គ្រឹះស្ថានត្រូវប្រើប្រាស់តួលេខប្រាក់ចំណេញសុទ្ធក្នុងរបាយការណ៍នោះវិញ។ ប្រាក់ចំណេញដែលអាចបែងចែកបានត្រូវគណនាបន្ទាប់ពីបង់ពន្ធរួច ដោយមិនគិតពីផលប៉ះពាល់នៃពន្ធទៅលើខ្ទង់ដែលអាចបែងចែកបាន។

## ២. ការពន្យល់បន្ថែមលើប្រការ ៥

***ប្រការ ៥.-***

*ក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា គ្រឹះស្ថានត្រូវមានទ្រនាប់ដើមទុនខនស៊ើវេសិន ដើម្បីធានាថាគ្រឹះស្ថានអាចទប់ទល់នឹងការធ្លាក់ចុះនៃដើមទុននៅពេលមានការខាតបង់។ នៅពេលទ្រនាប់ដើមទុនខនស៊ើវេសិនធ្លាក់ចុះមួយចំណែក ឬទាំងស្រុង គ្រឹះស្ថានត្រូវបំពេញឡើងវិញឱ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន។ ក្នុងករណីមិនអាចបំពេញបានភ្លាម គ្រឹះស្ថានត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវ "ផែនការគ្រប់គ្រងដើមទុន" ដោយត្រូវពន្យល់អំពីវិធីសាស្ត្រ និងកំណត់កាលបរិច្ឆេទដែលគ្រឹះស្ថានត្រូវបំពេញឡើងវិញនូវទ្រនាប់ដើមទុនខនស៊ើវេសិនដែលខ្វះនោះ។*

ដូចមានចែងនៅក្នុងប្រការ ១១ នៃប្រកាសស្តីពី ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អនុបាតដើមទុនខនស៊ើវេសិនអប្បបរមានៅចុងឆ្នាំហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការហាមឃាត់ការបែងចែកប្រាក់ចំណេញនៅឆ្នាំបន្ទាប់។ ក្នុងករណីដែលគ្រឹះស្ថានមិនអាចបំពេញទ្រនាប់ដើមទុនខនស៊ើវេសិនភ្លាមៗដោយប្រើប្រាស់ប្រាក់ចំណេញ គ្រឹះស្ថាននោះត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវផែនការគ្រប់គ្រងដើមទុន ដើម្បីឱ្យអនុបាតនោះគ្រប់គ្រាន់វិញឱ្យបានឆាប់រហ័ស។ ក្នុងស្ថានភាពធម្មតា គ្រឹះស្ថានមិនត្រូវកម្រិតទ្រនាប់ដើមទុននេះតែក្នុងចន្លោះណាមួយដើម្បីប្រកួតប្រជែងជាមួយគ្រឹះស្ថានផ្សេងទៀត និងដើម្បីទទួលបានចំណែកទីផ្សារធំនោះទេ។

ឧទាហរណ៍ នៅក្នុងខែមករា ឆ្នាំ២០១៩ គ្រឹះស្ថានមួយមានដើមទុនថ្នាក់ទី១ សរុប ៨% (ដើមទុនថ្នាក់ទី១ ស្មើ ៧,៥% និងទ្រនាប់ដើមទុន ០,៥%)។ ក្នុងករណីនេះ បើយោងតាមតារាង ១.១ ក្នុងឧបសម្ព័ន្ធ២ គ្រឹះស្ថានត្រូវរក្សា ៨០% នៃប្រាក់ចំណេញក្នុងឆ្នាំ២០១៨ ដើម្បីឱ្យស្របតាមការតម្រូវនៃទ្រនាប់ដើមទុន។ គ្រឹះស្ថានត្រូវតែរក្សាទុក ៨០% នៃប្រាក់ចំណេញឆ្នាំ២០១៨ ជាចំណេញរក្សាទុក និង ២០% អាចបែងចែកភាគលាភ ឬប្រាក់រង្វាន់បុគ្គលិកជាដើម។

នៅពេលដែលគ្រឹះស្ថានត្រូវអនុវត្តតាមកម្រិតអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន ២,៥% ក្នុងករណីគ្រឹះស្ថានមិនអាចបំពេញបាន គ្រឹះស្ថានត្រូវផ្ញើផែនការគ្រប់គ្រងដើមទុនដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ទៅធនាគារជាតិនៃកម្ពុជាភ្លាម ស្របតាមប្រការ ៥ នៃប្រកាស។

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវក្នុងការកំណត់អាទិភាព និងវាយតម្លៃជាបរិមាណច្បាស់លាស់ដែលប៉ះពាល់ដល់ដើមទុន ដែលធ្វើឱ្យគ្រឹះស្ថានមិនអាចបំពេញដើមទុនរបស់ខ្លួនបានទាន់ពេល ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍ដែលអាចនឹងកើតឡើងដោយមិនបានគិតទុកជាមុន។ ការរៀបចំផែនការគ្រប់គ្រងដើមទុន ក៏ត្រូវពិចារណាផងដែរនូវការកាត់បន្ថយ ឬការផ្អាកការបែងចែកភាគលាភ ការដាក់ដើមទុនថ្មីបន្ថែម ឬការបន្ថយទំហំតារាងតុល្យការជាដើម។ ធនាគារជាតិនៃកម្ពុជានឹងវាយតម្លៃអំពីភាពសមស្របនៃផែនការគ្រប់គ្រងដើមទុន។

## ៣. ការពន្យល់បន្ថែមលើប្រការ ៨

***ប្រការ ៨.-***

*ក្នុងករណីដែលគ្រឹះស្ថានមានកម្រិតអនុបាតដើមទុនថ្នាក់ទី១ លើសកម្រិតកំណត់អប្បបរមា (MCR1 = ៧,៥%) គ្រឹះស្ថានអាចប្រើប្រាស់ចំនួនទឹកប្រាក់ដើមទុនថ្នាក់ទី១ដែលលើស សម្រាប់បំពេញអនុបាតដើមទុនសរុបអប្បបរមា (MCRt = ១៥%) ប៉ុន្តែមិនអាចយកមកគណនាទ្រនាប់ដើមទុនខនស៊ើវេសិនរបស់គ្រឹះស្ថានបានទេ យោងតាមកម្រិតដើមទុនអប្បបរមា (MCR) ដែលមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។ ទម្រង់របាយការណ៍ និងការពន្យល់សម្រាប់ការគណនាកម្រិតទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ រៀងគ្នា។*

អនុបាតដើមទុនថ្នាក់ទី១ ដែលលើស ៧,៥% ត្រូវយកទៅបំពេញតាមការតម្រូវនៃអនុបាតដើមទុនសរុបអប្បបរមា (អនុបាតសាធនភាព) ជាមុន ទើបយកផ្នែកដែលនៅសល់ពីការបំពេញទៅធ្វើជាទ្រនាប់ដើមទុនខនស៊ើវេសិន។

***ករណីទី១***

*គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៦% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ និងអនុបាតដើមទុនថ្នាក់ទី២ មាន ៨% ស្មើគ្នា។ គ្រឹះស្ថានបានប្រើប្រាស់ ៧,៥% ក្នុងចំណោម ៨% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនថ្នាក់ទី១ និងដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ ០,៥% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ២% បន្ថែមទៀត ដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។*

*យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី១ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ០,៥% = ៨%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ១០០%។*

***ករណីទី២***

*គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៧% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ៩,៥% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៧,៥%។ គ្រឹះស្ថានបានប្រើប្រាស់ ៧,៥% ក្នុងចំណោម ៩,៥% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនថ្នាក់ទី១ និងដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់ ២% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ០,៥% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។*

*យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី៤ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ២% = ៩,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៤០%។*

***ករណីទី៣***

*គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៦,៥% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ១១,៥% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៥%។ គ្រឹះស្ថានបានប្រើប្រាស់ ១០% ក្នុងចំណោម ១១,៥% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១នៅសល់ ១,៥% សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ១% បន្ថែមទៀត ដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។*

*យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី៣ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ១,៥% = ៩%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៦០%។*

ក្នុងករណីនេះ ដើមទុនថ្នាក់ទី១ដែលលើសគឺ ៤% (១១,៥% - ៧,៥%) ប៉ុន្តែចំណែកដែលលើសនោះ មិនអាចយកទៅប្រើជាទ្រនាប់ដើមទុនខនស៊ើវេសិនទេ ព្រោះវិធាននៃកម្រិតដើមទុនអប្បបរមាគឺ ១៥%។ គ្រឹះស្ថានត្រូវប្រើ ១០% នៃ ១១,៥% ទៅបំពេញដើមទុនអប្បបរមាសិន (ដើមទុនថ្នាក់ទី១ 10% + ដើមទុនថ្នាក់ទី២ ៥%)។ ដូច្នេះ គ្រឹះស្ថាននៅសល់តែដើមទុន ១,៥% ប៉ុណ្ណោះ ដែលអាចយកទៅប្រើជាផ្នែកមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិន។ គ្រឹះស្ថានត្រូវបន្ថែមដើមទុនថ្នាក់ទី១ ១% ទៀតដើម្បីបង្គ្រប់កម្រិតអប្បបរមា ១០% (៧,៥% + ២,៥%)។

***ករណីទី៤***

*គ្រឹះស្ថានមួយមានអនុបាតសាធនភាព ១៥% ដែលសុទ្ធតែជាអនុបាតដើមទុនថ្នាក់ទី១។ គ្រឹះស្ថានត្រូវបានចាត់ទុកថា ពុំមានអនុបាតដើមទុនថ្នាក់ទី១ នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានត្រូវការអនុបាតដើមទុនថ្នាក់ទី១ ចំនួន ២,៥% បន្ថែមទៀតដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ។*

*យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី១ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ០% = ៧,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ១០០%។*

*ករណីទី៥*

*គ្រឹះស្ថានមួយ មានអនុបាតសាធនភាព ១៨% ដែលក្នុងនោះ អនុបាតដើមទុនថ្នាក់ទី១ មាន ១២% និងអនុបាតដើមទុនថ្នាក់ទី២ មាន ៦%។ គ្រឹះស្ថានបានប្រើប្រាស់ ៩% ក្នុងចំណោម ១២% នៃអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញកម្រិតដើមទុនអប្បបរមាសម្រាប់ដើមទុនសរុប។ គ្រឹះស្ថានត្រូវបានចាត់ទុកថាមានអនុបាតដើមទុនថ្នាក់ទី១ ចំនួន ៣% នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន។ ដូច្នេះ គ្រឹះស្ថានមិនត្រូវការអនុបាតដើមទុនថ្នាក់ទី១ ដើម្បីបំពេញតម្រូវការ ១០% ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។*

*យោងតាមតារាង១.២ គ្រឹះស្ថានអាចបែងចែកប្រាក់ចំណេញបានទាំងស្រុង។*

**ករណីទី៦**

គ្រឹះស្ថានមានអនុបាតសាធនភាពចំនួន ១៦% ដែលជាដើមទុនថ្នាក់ទី១ ទាំងអស់ គ្រឹះស្ថានអាចប្រើ១៥% ជាដើមទុនអប្បបរមា ដូច្នេះ មានន័យថា គ្រឹះស្ថានកំពុងអនុវត្តទ្រនាប់ដើមទុនខនស៊ើវេសិន ១% រួចហើយ ប៉ុន្តែ គ្រឹះស្ថានត្រូវការបន្ថែមទ្រនាប់ដើមទុននេះ ១,៥% ទៀត។

យោងតាមតារាង១.២ គ្រឹះស្ថានត្រូវស្ថិតក្នុងចតុភាគទី២ នៃទ្រនាប់ដើមទុនថ្នាក់ទី១ (MCR1 + អនុបាតដើមទុនថ្នាក់ទី១នៅសល់សម្រាប់បំពេញទ្រនាប់ដើមទុន = ៧,៥% + ១% = ៨,៥%) ដែលក្នុងករណីនេះ គ្រឹះស្ថានត្រូវរក្សាទុកប្រាក់ចំណេញ ៨០%។

## ៤. ការពន្យល់បន្ថែមលើប្រការ ៩

***ប្រការ ៩***.-

*ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុត្រូវបានហាមឃាត់ នៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ (MCR1=៧,៥%) របស់គ្រឹះស្ថាន ស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិនដូចមានចែងនៅក្នុងប្រការ ១១ នៃប្រកាសនេះ។ ការហាមឃាត់នេះ អនុវត្តចំពោះការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុតែប៉ុណ្ណោះ ដោយមិនប៉ះពាល់ដល់ដំណើរការប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានឡើយ។*

គ្រឹះស្ថានត្រូវរក្សាអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនលើសពីកម្រិតដើមទុនថ្នាក់ទី១ អប្បបរមា (៧,៥%)។ ក្នុងអំឡុងពេលធម្មតា គ្រឹះស្ថានត្រូវរក្សាកម្រិតដើមទុនថ្នាក់ទី១អប្បបរមា ១០%។ ក្នុងករណីអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនធ្លាក់ក្នុងចន្លោះពី ០% ទៅ ២,៥% នោះការបែងចែកភាគលាភនឹងត្រូវបានហាមឃាត់។ ការហាមឃាត់នេះគឺអនុវត្តចំពោះការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ ដូចជា ភាគលាភ តែប៉ុណ្ណោះ ដោយមិនប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានទេ។

ទោះបីជាទ្រនាប់ដើមទុនមានគោលដៅកាត់បន្ថយភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុ ដើម្បីចៀសវាងការមិនគោរពតាមកម្រិតកំណត់ដើមទុនអប្បបរមា ទ្រនាប់ដើមទុនមិនត្រូវបានចាត់ទុកថាជាដើមទុនអប្បបរមាថ្មីទេ។ ប្រាក់ចំណេញរក្សាទុក ត្រូវប្រើប្រាស់ជាជម្រើសទីមួយក្នុងការបំពេញទ្រនាប់ដើមទុនឡើងវិញ។

## ៥. ការពន្យល់បន្ថែមលើប្រការ ១០

***ប្រការ ១០.-***

*ការបែងចែកដែលអាចប៉ះពាល់ដល់ដើមទុនថ្នាក់ទី១ ត្រូវបានហាមឃាត់មានដូចជា ការបែងចែកភាគលាភ ការទិញភាគហ៊ុនត្រលប់មកវិញ និងការទូទាត់លើប្រាក់រង្វាន់បុគ្គលិក ជាដើម។*

គ្រឹះស្ថានត្រូវមានគោលនយោបាយអភិបាលកិច្ចច្បាស់លាស់ពាក់ព័ន្ធនឹងការបែងចែកប្រាក់រង្វាន់ដល់គណៈគ្រប់គ្រងនិងបុគ្គលិក និងត្រូវមានផែនការដើមទុន មុនពេលបែងចែកប្រាក់ចំណេញដែលអាចប៉ះពាល់ដល់ដើមទុនថ្នាក់ទី១។

ផែនការដើមទុនត្រូវធានាថា ការបែងចែកប្រាក់រង្វាន់បុគ្គលិកមិនត្រូវធ្វើឡើង មុនការគណនាអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនទេ។ រាល់គម្រោងផ្តល់ប្រាក់រង្វាន់បុគ្គលិកត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ ដោយចៀសវាងការបែងចែកប្រាក់ចំណេញរក្សាទុកដែលត្រូវទុកសម្រាប់បំពេញបង្គ្រប់ ឬបង្កើនទ្រនាប់ដើមទុន។

អនុបាតដើមទុនថ្នាក់ទី១នៅចុងឆ្នាំហិរញ្ញវត្ថុ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់គណនាការបែងចែកប្រាក់ចំណេញនៅឆ្នាំហិរញ្ញវត្ថុបន្ទាប់។ ជាធម្មតា ប្រាក់រង្វាន់បុគ្គលិក ត្រូវបានកំណត់ទុកនៅឆ្នាំហិរញ្ញវត្ថុមុន (t-1) ហើយត្រូវបានបែងចែកនៅក្នុងត្រីមាសទី១ នៃឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន (t)។ ដើម្បីគណនាការបែងចែកប្រាក់ចំណេញឱ្យបានត្រឹមត្រូវ ប្រាក់រង្វាន់បុគ្គលិកដែលត្រូវបានកំណត់ទុកមុនត្រូវបូកបញ្ចូលទៅក្នុងប្រាក់ចំណេញសុទ្ធ ដើម្បីរក្សាកម្រិតអនុបាតដើមទុនថ្នាក់ទី១ និងអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនអប្បបរមា។

## ៦. ការពន្យល់បន្ថែមលើប្រការ ២០

***ប្រការ ២០.-***

*ដោយឡែក គ្រឹះស្ថានដែលធនាគារជាតិនៃកម្ពុជាតម្រូវឱ្យរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមា ត្រូវអនុវត្តបញ្ញត្តិដូចខាងក្រោម៖*

- *គ្រឹះស្ថានដែលមានកាតព្វកិច្ចបង្កើនអនុបាតសាធនភាព កម្រិតដើមទុនអប្បបរមាសម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលជាកម្រិតដើមទុនអប្បបរមា ១៥% ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ បូកនឹងកាតព្វកិច្ចដើមទុនដែលបានតម្រូវឱ្យបង្កើនបន្ថែមដូចមានចែងក្នុងប្រការ ៦ នៃ*



h

*ប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត។*

- *ធនាគារជាតិនៃកម្ពុជា អាចកំណត់ទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលផ្សេងៗគ្នាចំពោះគ្រឹះស្ថាន ដែលទ្រនាប់ដើមទុនទាំងពីរនេះសរុបមិនលើសពីកម្រិត ២,៥% លើកម្រិតដើមទុនអប្បបរមាដែលបានបន្ថែមរួចហើយ និងមិនតិចជាងកម្រិតដើមទុនអប្បបរមាដែលបានចែងក្នុងប្រការ ៧ និងប្រការ ១៤ នៃប្រកាសនេះ។*
- *គ្រឹះស្ថានដែលត្រូវរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមានឹងត្រូវអនុវត្តតាមការកំណត់ដោយឡែករបស់ធនាគារជាតិនៃកម្ពុជា។*

គ្រឹះស្ថានដែលតម្រូវឱ្យបង្កើនអនុបាតសាធនភាពបន្ថែមដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម៖

- <u>គោលការណ៍ទី១</u>៖ គ្រឹះស្ថាននីមួយៗត្រូវអនុវត្តស្របតាមកម្រិតនៃទ្រនាប់ដើមទុន ពោលគឺទ្រនាប់ដើមទុនខនស៊ើវេសិន ២,៥% និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល មិនលើសពី ២,៥%។ សម្រាប់ការគណនាអនុបាតខនស៊ើវេសិន គ្រឹះស្ថានត្រូវអនុវត្តតាមប្រការ ៤ ប៉ុន្តែកម្រិតដើមទុនអប្បបរមា (MCR) និងអនុបាតដើមទុនថ្នាក់ទី១ អប្បបរមា (MCR1) ត្រូវស្របតាមប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក។
- <u>គោលការណ៍ទី២</u>៖ យោងតាមប្រការ ២០ និងប្រការ ១៥ ប្រសិនបើអនុបាតទ្រនាប់ដើមទុននិងអនុបាតដើមទុនបន្ថែមមានលក្ខណៈតឹងពេក ធនាគារជាតិនៃកម្ពុជាអាចផ្លាស់ប្តូរកម្រិតអនុបាតខោនធើស៊ីឃ្លីខលដោយផ្អែកលើកម្រិតហានិភ័យជាប្រព័ន្ធរបស់គ្រឹះស្ថាន។

ឧទាហរណ៍៖ ទ្រនាប់ដើមទុនខនស៊ើវេសិនស្មើ ២,៥% ហើយទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលស្មើ ២%។ សម្រាប់ការគណនាអនុបាតខនស៊ើវេសិនអប្បបរមា សូមមើលតារាងក្នុងឧបសម្ព័ន្ធ៣ និងឧទាហរណ៍ ដូចខាងក្រោម៖

<u>ឧទាហរណ៍ទី១</u>៖ ប្រសិនបើគ្រឹះស្ថាន XYZ ត្រូវបានធនាគារជាតិនៃកម្ពុជាតម្រូវឱ្យបង្កើនអនុបាតសាធនភាព ៣% បន្ថែមលើដើមទុនអប្បបរមា (១៥%) គ្រឹះស្ថានត្រូវអនុវត្តតាមការកំណត់អនុបាតទ្រនាប់ដើមទុនទាំងពីរជាមួយនឹងដើមទុនអប្បបរមាថ្មី។ ក្នុងករណីនេះ ដើមទុនអប្បបរមាស្មើ ១៨% (១៥% + ៣%) ហើយដើមទុនថ្នាក់ទី១ ត្រូវធំជាងឬស្មើ ៥០% នៃដើមទុនសរុប មានន័យថាដើមទុនថ្នាក់ទី១ ថ្មីធំជាងឬស្មើ ៩%។ ដូច្នេះ គ្រឹះស្ថានមិនមានដើមទុននៅសល់សម្រាប់ទ្រនាប់ដើមទុនទេ (ទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល) ក្នុងករណីដែលអនុបាតសាធនភាពរបស់គ្រឹះស្ថាន XYZ ស្មើ ១៨% និងដើមទុនថ្នាក់ទី១ ស្មើ ៩%។

<u>ឧទាហរណ៍ទី២</u>៖ ធនាគារជាតិនៃកម្ពុជាបានកំណត់ឱ្យគ្រឹះស្ថាន XYZ មានកម្រិតដើមទុនអប្បបរមា ១៦% ផ្អែកលើការវាយតម្លៃហានិភ័យ។ ដូច្នេះ គ្រឹះស្ថានត្រូវមានដើមទុនសរុប ២០,៥% ក្នុងនោះ កម្រិតដើមទុនអប្បបរមា ១៦% ទ្រនាប់ដើមទុនខនស៊ើវេសិន ២,៥% និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ២% (យោងឧបសម្ព័ន្ធ៣នៃប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)។

ជាក់ស្តែង គ្រឹះស្ថានមានអនុបាតសាធនភាព១៨% ក្នុងនោះដើមទុនថ្នាក់ទី១ ចំនួន ១០%។ ដូច្នេះ គ្រឹះស្ថាន XYZ មានទ្រនាប់ដើមទុនខនស៊ើវេសិន ២% រួចជាស្រេច។ ដូច្នេះ គ្រឹះស្ថាន XYZ ត្រូវបង្កើតទ្រនាប់ដើមទុនខនស៊ើវេសិនបន្ថែម ០,៥% និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ២% ដើម្បីមានដើមទុនសរុប ២០,៥% ។

សារាចរណែនាំបន្ថែមនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសាភិបាល**

**ជា_ចាន់តូ**